U.S. EMBASSY

PRESS RELEASE

សេចក្តីប្រកាសពត៌មាន

# សហរដ្ឋអាមេរិកផ្តល់ជំនួយឧបត្ថម្ភសរុបចំនួន ៣៤,៧ លានដុល្លារ សំរាប់កម្មវិធីសុខភាពនិងការអប់រំជាមូលដ្ឋាននៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងចំនួនពីរ ផ្តល់ថវិកាសរុបចំនួន ៣៤,៧ លានដុល្លាសហរដ្ឋអាមេរិក ក្នុងនាមជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ដើម្បីជួយពង្រឹងផ្នែកសុខភាព និងការអប់រំនៅកម្ពុជា ។ ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លោក ឆាល អេ រ៉េ ឯកអគ្គរដ្ឋទូតសហរដ្ឋ-អាមេរិកប្រចាំនៅកម្ពុជា និង លោក យ៉ូណាថាន អែដុលតុន នាយកបេសកម្មរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ប្រចាំកម្ពុជា នឹងចូលរួមនៅក្នុងពិធីចុះហត្ថលេខានេះ ។

កិច្ចព្រមព្រៀងទី ១ផ្តល់ជាថវិកាសរុបចំនួន ២៨,៧ លានដុល្លាសហរដ្ឋអាមេរិក ដើម្បីពង្រឹងបញ្ហាសុខភាពជាចំបង ។ ជំនួយនេះនឹងប្រើសំរាប់ធ្វើឱ្យប្រសើរឡើងនូវរាល់សកម្មភាព ដែលពាក់ព័ន្ធនឹងបញ្ហាជំងឺ *ហ៊ីវ/អេដស៍* និងជំងឺឆ្លងផ្សេងៗទៀត សុខមាលភាពមាតានិងទារក និងពង្រឹងនូវប្រព័ន្ធសុខភាព សាធារណៈ ដោយរួមបញ្ចូលទាំងការពង្រឹងបន្ថែមនូវជំនាញបច្ចេកទេសសំរាប់បុគ្គលិកសុខាភិបាលកម្ពុជា ។ គំរោងកម្មវិធីនេះនឹងអនុវត្តដោយអង្គការជាតិ និងអន្តរជាតិជាច្រើន ដែលបានធ្វើការសហប្រតិបត្តិការគ្នាយ៉ាងជិតស្និទ្ធ ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នអ្នកផ្តល់ជំនួយផ្សេងៗទៀត ។

កិច្ចព្រមព្រៀងទី២ ផ្តល់ថវិកាសរុបចំនួន៦លានដុល្លាសហរដ្ឋអាមេរិក ដើម្បីពង្រឹងនូវកម្មវិធីអប់រំជាមូលដ្ឋាននៅកម្ពុជា ។ ជំនួយនេះនឹងប្រើសំរាប់ពង្រឹងនូវគំរោងសកម្មភាពដែលកំពុងបន្ត ក្នុងគោលបំណងដើម្បីធ្វើឱ្យប្រសើរឡើងកម្មវិធីសិក្សា និងពង្រីកលទ្ធភាពចូលរៀនឱ្យកាន់តែច្រើនឡើង រួមបញ្ចូលទាំងជនជាតិភាគតិចកម្ពុជា និងអ្នកបាត់បង់លទ្ធភាពពលកម្មផងដែរ ។ គំរោងកម្មវិធីនេះក៏បានបង្កើតឡើងដើម្បីជំរុញឱ្យមានភាពប្រសើរឡើងនូវគុណភាពនៃការអប់រំ កាត់បន្ថយនូវការបោះបង់ចោលសាលា បណ្តុះបណ្តាលគ្រូបង្រៀនបន្ថែម និងបង្កើតកម្មវិធីសិក្សានៅក្នុងថ្នាក់ ឱ្យកាន់តែមានទំនាក់ទំនងទៅនឹងកម្មវិធីក្នុងសតវត្សរ៍ទី ២១នេះ ។

**<u>ពិធីចុះហត្ថលេខានេះនឹងប្រព្រឹត្តទៅ នៅថ្ងៃព្រហស្បតិ៍ ទី៣០ ខែមិថុនា ឆ្នាំ២០០៥ វេលាម៉ោង ៤:៣០ នាទីរសៀល នៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ</u>** ។ សូមអញ្ជើញអ្នកកាសែតចូលរួមយកពត៌មាននៅក្នុងពិធីចុះហត្ថលេខានេះ ។

Public Affairs Section
20 Mongkol Iem Street 228, Phnom Penh
Tel: 216 436/38, Ext. 163 / 258 - Fax: 217 637

ការិយាល័យទំនាក់ទំនងកិច្ចការសាធារណៈ
ផ្ទះលេខ២០ ផ្លូវមង្គលអៀម(ផ្លូវ២២៨)
ទូរស័ព្ទលេខ: ២១៦៤៣៦ / ៣៨ ភ្ជាប់មក ១៦៣ / ២៥៨